ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

សីហា ២០០៦ / August 2006

ផាន់ ដាលីស / **Phann Dalis**

ប៉ុន ដូរីណា / **Pon Dorina**

ហ៊ីង វុត្ថា / **Hing Vutha**

ភីម រុនស៊ីណារិទ្ធិ / **Phim Runsinarith**

បកប្រែដោយៈ យូ សិទ្ធីរិទ្ធ និង យេន សុផានី

ភ្នំពេញ កម្ពុជា

**Phnom Penh, Cambodia**

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh. *Web site:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា
# Main Economic Activities of Cambodia

នៅត្រីមាសទី១ ២០០៦ តំលៃវិនិយោគឯកជនសរុបក្នុងវិស័យសេវាកម្ម បានអនុម័តដោយ CDC មានរហូតដល់ ៦០.៧លានដុល្លារ ក្នុងនេះ ៩៦.៦% ជាវិនិយោគក្នុងវិស័យសាងសង់ និង ៤% ជាវិនិយោគ ក្នុងវិស័យថាមពល ។ ក្នុងវិនិយោគខាងសាងសង់ ៦០% ជារបស់វិនិយោគិនកម្ពុជា ។ សេវាកម្មផ្សេងទៀត បានកើនឡើង ១១ដង ដល់ ៦០.៥លានដុល្លារ ធៀបនឹង ៥.៥លានដុល្លារនៅត្រីមាសមុន និង ៦.៩លានដុល្លារ នៅត្រីមាសដូចគ្នា ឆ្នាំមុន ។

The total value of private investment in the service sector approved by the Council for the Development of Cambodia in the first quarter of 2006 amounted to USD60.7 m. Ninety-six percent of this amount was invested in construction and four percent in energy. Of total investment in construction, 60 percent was invested by Cambodians. Other services increased eleven times to USD60.5 m, compared with USD5.5 m in the preceding quarter and USD6.9 m in the same quarter last year.

### Private Investment in Service Sector Approved by CDC 2003 Q3–2006 Q1




*Including expansion projects.*
Source: Council for the Development of Cambodia

នៅខែឧសភា ២០០៦ ភ្ញៀវបរទេសមកដល់កម្ពុជាមានសរុប ១០៧.៧១៧ នាក់ រឺ ២៤.៧% ទាបជាងខែមុន ។ ភ្ញៀវមកតាមផ្លូវគោក និងទឹក មាន ៤៥.០០៧នាក់ រឺថយចុះអស់ ៣៣% បើធៀបនឹងខែមុន ។ ភ្ញៀវមកតាមផ្លូវអាកាសថយចុះ ១៧.៤% ពី ៧៥.៨៩០នាក់ មកត្រឹម ៦២.៧១០នាក់ ។

In May, the number of foreign visitor arrivals totalled 107,717 persons, 24.7 percent lower than the previous month. Visitors arriving by land and water amounted to 45,007 persons, a decline of 33 percent from last month. Visitors arriving by air decreased by 17.4 percent, from 75,890 persons to 62,710 persons.

### Foreign Visitor Arrivals in Cambodia by Air, Land and Water March 05–May 06




Source: Ministry of Tourism

នៅខែឧសភា គំរោងសាងសង់បានអនុម័តដោយនាយកដ្ឋានសុរិយោដីក្រុងភ្នំពេញ មានតំលៃ ៤០.៩លានដុល្លារ ធៀបនឹង ១២.២លាននៅខែមេសា ។ ការអនុមតិគំរោងផ្ទះល្វែង កើនពី ៦.៨លានដុល្លារ នៅខែមេសា ដល់ ២៤.៣លាន នៅខែឧសភា ។ តំលៃគំរោងភូមិគ្រឹះនិងផ្ទះដែលបានអនុម័តកើនទ្វេដងដល់ ២.១លានដុល្លារ រីឯ តំលៃគំរោងសំណង់ផ្សេងទៀត កើនដល់ ១៤.៥ លានដុល្លារ ធៀបនឹង ៤.៥លានដុល្លារ នៅខែមុន ។

Construction projects approved by the Department of Cadastre and Geography of the Municipality of Phnom Penh were valued at USD40.9 m in May, up from USD12.2 m in April. Flat approvals increased from USD6.8 m in April to USD24.3 m in May. The value of villa and house approvals doubled to USD2.1 m, while other construction rose to USD14.5 m, compared to USD4.5 m in the preceding month.

### Value of Construction Approvals in Phnom Penh March 05–May 06




Source: Phnom Penh municipality

# អត្រាការប្រាក់ និង ថ្លៃទំនិញ

# Price and Interest Rate Developments

នៅភ្នំពេញ ថ្លៃសាំង និងម៉ាស៊ូតនៅទីផ្សារ បន្តកើនឡើងអស់៤ខែមកហើយ។ នៅខែកក្កដា ២006 ថ្លៃសាំងជាមធ្យមកើន ១,២១% ដល់ ៤១៣៧រៀល/លីត្រ ធៀបនឹងកំណើន ៣,៨១% នៅខែមិថុនា ។ នៅពេលជាមួយគ្នា ថ្លៃម៉ាស៊ូតជាមធ្យម កើន ៣,0% ដល់ ៣៣0៥រៀល/លីត្រ ធៀបនឹងកំណើន ២,៤២% នៅខែមិថុនា ។

The market prices of gasoline and diesel oil in Phnom Penh have increased in each of the last four months. In July, the average price of gasoline rose by 1.21 percent to 4137 riels/litre, compared to a 3.81 percent increase in June. The average price of diesel fuel increased by 3.0 percent to 3305 riels/litre, compared to a 2.42 percent rise in June.

**Gasoline and Diesel Prices: Phnom Penh May 2005–July 2006**




Sources: CDRI and National Institute of Statistics

នៅខែមិថុនា សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ទូទៅនៅភ្នំពេញ កើនបន្តិចបាន 0,៤% ធៀបនឹងខែឧសភា ។ សន្ទស្សន៍ថ្លៃដឹកជញ្ជូន និង ទូរគមនាគមន៍ កើនបាន ១,២% រីឯសន្ទស្សន៍ថ្លៃម្ហូបអាហារកើនបាន 0,១% ។ ធៀបនឹងខែមិថុនា ឆ្នាំមុន ថ្លៃទំនិញទូទៅ កើនបាន ៣,៨២% ។ ក្នុងកំឡុងពេលនេះដែរ ថ្លៃម្ហូបអាហារ និង ថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍ កើនបាន ៤,៣% និង ១0,១% រៀងគ្នា ។

The overall consumer price index in Phnom Penh rose by 0.4 percent in June, compared to May. The price index for transportation and communication grew by 1.2 percent, while the food price index increased by 0.1 percent. Compared to June last year, overall prices increased 3.82 percent. During this time, prices of food and of transportation and communication rose by 4.3 percent and 10.1 percent, respectively.

**Consumer Price Index**
(July–December 2000=100)




Source: National Institute of Statistics

យោងតាមធនាគារជាតិនៃកម្ពុជា នៅខែឧសភា អត្រាការប្រាក់លើកំចីរយៈ ១២ខែ (រៀល) ផ្តល់ដោយធនាគារពាណិជ្ជកម្មក្រៅប្រទេស FTB គឺ ១៨% ធៀបនឹងអត្រា ២៤% របស់ធនាគារ កាណាឌីយ៉ា និងអេស៊ីលីដា ។ ចំពោះកំចីជាដុល្លារ ធនាគារទាំងបី មានអត្រា ១៨% ស្មើគ្នា ។ ធៀបនឹងខែឧសភា ២00៥ FTB និង កាណាឌីយ៉ា មានអត្រាការប្រាក់នៅថេរទាំងសំរាប់កំចីជារៀល និងដុល្លារ រីឯ អេស៊ីលីដា បានបង្កើនអត្រាការប្រាក់ 0,៣% លើកំចីជាដុល្លារ ។

According to the National Bank of Cambodia, the interest rate on 12-month loans in riels offered in May by the Foreign Trade Bank (FTB) was 18 percent, compared to 24 percent quoted by Canadia Bank and ACLEDA. For US dollar loans, the three banks had the same rate, 18 percent. Compared to May 2005, the FTB and Canadia Bank have had stable interest rates for both riel and dollar loans, while ACLEDA has increased its rate by 0.3 percent on dollar loans.

**Interest Rates on 12-Month Loans**
(As of May 2006)




Source: National Bank of Cambodia

# ស្ថានភាពអត្រាប្តូរប្រាក់ និង រូបិយវត្ថុ

# Exchange Rates and Monetary Developments

នៅខែកក្កដា ២០០៦ ប្រាក់រៀលកម្ពុជា បានធ្លាក់ថ្លៃទល់នឹង ដុល្លារUS ដោយប្តូរបាន ៤១២២រៀល/ដុល្លារ ធៀបនឹង ៤១១៨រៀល/ដុល្លារ នៅខែមុន ។ ធៀបនឹងពេលដូចគ្នា ឆ្នាំមុន ប្រាក់រៀលឡើងថ្លៃបាន ១,៥% ទល់នឹងដុល្លារUS ។

In July, the riel depreciated against the US dollar, trading at 4122 riels/USD, compared with 4118 riels/USD the previous month. Compared to last year at the same time, the riel has appreciated by 1.5 percent against the dollar.

**Riels per US Dollar**
**May 2005–July 2006**




Sources: National Bank of Cambodia and CDRI

នៅខែកក្កដា អត្រាប្តូរប្រាក់រវាងប្រាក់រៀល និងប្រាក់បាតថៃ គឺ ១០៩រៀល/បាត ធៀបនឹង ១០៨រៀល/បាត នៅខែមុន រឺ ធ្លាក់ចុះអស់ ០,៩% ។ ទល់នឹងប្រាក់ដុងវៀតណាម ប្រាក់រៀលមានស្ថិរភាព ក្នុងខែកក្កដានេះ ដោយមានអត្រាប្តូរជាមធ្យម ២៥រៀល/១០០ដុង ។ ធៀបនឹងខែកក្កដា ឆ្នាំមុន ប្រាក់រៀលឡើងថ្លៃបាន ៣,៨% ។

The exchange rate between the riel and the Thai baht in July was 109 riels/THB, a decline of 0.9 percent from 108 riels/THB the preceding month. Against the Vietnamese dong, the riel was stable in July at 25 riels per 100 dong. Compared to July last year, this was a 3.8 percent appreciation.

**Riels against THB and VND**
**May 2005–July 2006**




Source: CDRI

នៅខែឧសភា ២០០៦ រូបិយវត្ថុទូទៅ កើនដល់ ៥៩៦៤ពាន់លានរៀល រឺ ១,០% ច្រើនជាងនៅខែមុន និង ២៧,៥% ច្រើនជាងខែដូចគ្នា ឆ្នាំមុន ។ ក្នុងរូបិយវត្ថុទូទៅនេះ ប្រាក់បញ្ញើជារូបិយវត្ថុបរទេស កើនបាន ៣០% ដល់ ៤៣៧៥ពាន់លានរៀល ។ ប្រាក់រៀលចរាចរនៅក្រៅធនាគារ កើន ២៣% ដល់ ១៤២៧ពាន់លានរៀល រីឯប្រាក់រៀលជាបញ្ញើនៅធនាគារ ថយចុះ មកត្រឹម ១៦២ពាន់លានរៀល រឺថយចុះ ០,៦% បើធៀបនឹងចុងខែឧសភា ២០០៥ ។

In May, the money supply (M2) was KHR5964 bn, 1.0 percent increase from the previous month and 27.5 percent rise from the same month last year. Of the total liquidity, foreign currency deposits expanded by 30 percent to KHR4375 bn. Riels in circulation rose by 23 percent to KHR1427 bn, while riels in bank deposits decreased by 0.6 percent to KHR162 bn, compared with the end of May 2005.

**Monetary Liquidity**
**March 2005–May 2006**




** Revised*
Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស
# External Trade

នៅខែឧសភា ២០០៦ ការនាំចេញសរុបរបស់កម្ពុជា មាន ១៩៨លានដុល្លារ ឺ ៣២% ខ្ពស់ជាងខែមេសា ។ ការនាំចេញសំលៀកបំពាក់ កើនបាន ៣១% ដល់ ១៩០លានដុល្លារ និងការនាំចេញកៅស៊ូ កើនបាន ៧៣% ដល់ ៣,៨លានដុល្លារ ។ ប៉ុន្តែ ការនាំចេញត្រី បានធ្លាក់ចុះអស់ ៤០% មកត្រឹម ០,៣លានដុល្លារ ធៀបនឹងខែមេសា ។

Exports from Cambodia in May totalled USD198 m, 32 percent more than in April. Garment exports rose by 31 percent to USD190 m and rubber exports increased by 73 percent to USD3.8 m. However, fish exports decreased by 40 percent to USD0.3 m.

**Cambodia: Main Exports**
**March 05–May 06**




Source: Customs and Excise Department

នៅខែឧសភា ការនាំចូលស៊ីម៉ង់ត៍ និងដែក មានតំលៃ ២៩,៤ពាន់លានរៀល ឺ ៤,៥% តិចជាងខែមុន ។ ក្នុងនេះ ការនាំចូលស៊ីម៉ង់ត៍ កើនបាន ១១% ដល់ ២០,៣ពាន់លានរៀល រីឯការនាំចូលដែកធ្លាក់ចុះអស់ ២៧% មកត្រឹម ៩,១ពាន់លានរៀល ។ នៅពេលជាមួយគ្នា ការនាំចូលបារី ធ្លាក់ចុះអស់ ១៧% មកត្រឹម ២៩,៤ពាន់លានរៀល ។

In May, the total value of cement and steel imports was KHR29.4 bn, 4.5 percent less than the previous month. Cement imports rose by 11 percent to KHR 20.3 bn, but steel declined by 27 percent to KHR 9.1 bn. Imports of cigarettes decreased by 17 percent from the previous month, to KHR29.4 bn.

**Imports of Cigarettes and Construction Material**
**March 05–May 06**




Source: Control Office, Customs and Excise Department

នៅខែឧសភា ២០០៦ កម្ពុជានាំចូលសាំង ១១.២៧០តោន និងម៉ាស៊ូត ៤៤.៣៤០តោន ។ ការនាំចូលម៉ាស៊ូត កើន ១៦% ធៀបនឹងខែមុន រីឯការនាំចូលសាំង ថយចុះ ១៦% ។ ប៉ុន្តែ ការនាំចូលទាំងសាំង និងម៉ាស៊ូត មានកំរិតខ្ពស់ជាងនៅខែដូចគ្នា ឆ្នាំមុន ដល់ ៣,១% និង ៣០% រៀងគ្នា ។

Cambodia imported a total of 11,270 tonnes of gasoline and 44,340 tons of diesel oil in May. Diesel imports increased by 16 percent from the previous month, while gasoline imports decreased 16 percent. Imports of both gasoline and diesel were higher than in the same month last year, by 3.1 percent and 30 percent, respectively.

**Petroleum Product Imports**
**March 05–May 06**




Source: Control Office, Customs and Excise Department

# ប្រភព និងការប្រើប្រាស់ជំនួយបរទេស

# Sources and Uses of Foreign Assistance

វិស័យធនធានធម្មជាតិ រួមមាន ការរក្សាបរិស្ថាន ការរុករករ៉ែ សត្វព្រៃនិងឧទ្យានជាតិ ធនធាននៅបាតសមុទ្រ ។ល។ បានទទួលជំនួយបរទេស ៧៣,៨ លានដុល្លារពីឆ្នាំ១៩៩៦-២០០៥ ដែលតំណាងឱ្យ ២,៨%នៃការបើកផ្តល់សរុប ២៦២២,៤លានដុល្លារ (សំរាប់ ១៦វិស័យ) ។ នៅឆ្នាំ២០០៥ វិស័យធនធានធម្មជាតិ ទទួលបាន ១៩,៧លានដុល្លារ រឺ ៣,៨%នៃការបើកផ្តល់សរុប ។

The three charts on this page focus on aspects of foreign assistance to Cambodia: natural resources, energy and social development.

The natural resources sector, i.e. environment preservation, mineral exploration, wildlife and national parks, sea-bed resources etc., received USD73.8 m of foreign assistance during 1996–2005, accounting for 2.8 percent of total disbursements USD 2622.4 m (for 16 sectors). In 2005, the natural resources sector received USD19.7 m, 3.8 percent of the total disbursement.

**External Development Assistance Disbursement for Natural Resources 1996–2005**




Source: Council for the Development of Cambodia

វិស័យថាមពល ដែលមាន ប្រភពថាមពលកកើតឡើងវិញ វារីអគ្គិសនីនិងការបញ្ជូនថាមពល ប្រភពថាមពលធម្មតា និងការសំចៃថាមពល ទទួលបាន ៥៩,៧លានដុល្លារ រឺ ២,៣%នៃជំនួយអភិវឌ្ឍន៏បរទេស ពីឆ្នាំ១៩៩៦-២០០៥។ យោងតាមក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា មានការបើកផ្តល់ ១៤,៥លានដុល្លារ (២,៧%នៃជំនួយបរទេសសរុប ៥២៤,៩លានដុល្លារ) សំរាប់វិស័យនេះ ។

The energy sector, i.e. renewable energy sources, hydroelectric power generation and transmission, conventional energy sources and energy conservation, received USD59.7 m, 2.3 percent of external development assistance during 1996–2005. According to the CDC, USD 14.5 m (2.7 percent of total assistance of USD 524.9 m) was disbursed in this sector.

**External Development Assistance Disbursement for Energy 1996–2005**




Source: Council for the Development of Cambodia

ការបើកផ្តល់ជំនួយបរទេសសរុប សំរាប់វិស័យអភិវឌ្ឍន៏សង្គម ដែលមាន ច្បាប់សង្គមកិច្ច ការអភិវឌ្ឍន៏ទីក្រុង ទឹកស្អាតនិងអនាម័យ ការទប់ស្កាត់បទល្មើស ពីឆ្នាំ១៩៩៦-២០០៥ មាន ២៩៨,៧លានដុល្លារ ។ នៅឆ្នាំ២០០៥ ថវិកា ៤០,៣លានដុល្លារ បានប្រើសំរាប់វិស័យនេះ (រឺ ៧,៧%នៃចំនួនសរុប) ដែលផ្តល់ឱ្យជាសំខាន់ដោយ បារាំង អូស្ត្រាលី ធនាគារពិភពលោក ទីភ្នាក់ងារនានានៃUN និងធនាគារអភិវឌ្ឍន៏អាស៊ី ។

Total external assistance disbursements for social development, i.e. social legislation, urban development, drinking water and sanitation, crime prevention, from 1996 to 2005 were USD298.7 m. In 2005, USD40.3 m was used for this sector, 7.7 percent of the total; this was mainly provided by France, Australia, World Bank, UN agencies and ADB.

**External Development Assistance Disbursement for Social Development 1996–2005**




Source: Council for the Development of Cambodia

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

យោងតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅខែមីនា ២០០៦ ប្រតិបត្តិការថវិកាចរន្តរបស់កម្ពុជា មានអតិរេកថយចុះមកត្រឹម ៣២ពាន់លានរៀល ធៀបនឹង ៣៩ពាន់លានរៀល នៅខែមុន ។ រឿងនេះឆ្លុះបញ្ចាំងពីកំណើន ២០% ក្នុងចំណាយចរន្តនៅកំឡុងពេលនេះ ។

According to the Ministry of Economy and Finance, Cambodia’s current budget operation surplus fell to KHR32 bn in March, compared to KHR39 bn in the previous month. This reflects an increase of 20 percent in current expenditure during the period.

**Balance of Current Budget Operations**
**January 2005–March 2006**




*Note: Provisional for 2005–2006*
Source: *Monthly Bulletin of Statistics* (MEF)

នៅខែមីនា ចំណូលថវិកាចរន្ត ដែលស្ទើរតែស្មើចំណូលថវិកាក្នុងស្រុកសរុប កើនបាន ១២% ដល់ ២១១,៥ពាន់លានរៀល ធៀបនឹង ១៨៩,៥ ពាន់លានរៀល នៅខែកុម្ភៈ ។ ក្នុងកំឡុងពេលដូចគ្នា ចំណូលមិនមែនពន្ធ ពន្ធក្នុងស្រុក និង ពន្ធនាំចេញនាំចូល កើនបាន ១៤%, ៤,១% និង ១៥% ។

Current revenue, which almost equals total domestic revenue, rose by 12 percent from KHR189.5 in February to KHR211.5 bn in March. During the same period, non-tax revenue increased by 14 percent, domestic taxes by 4.1 percent and import and export taxes by 15 percent.

**Current Budget Revenue**
**January 2005–March 2006**




*Note: Provisional for 2005–2006*
Source: *Monthly Bulletin of Statistics* (MEF)

នៅខែមីនា ចំនាយថវិកាចរន្ត កើនបាន ២០% ដល់ ១៨០ពាន់លានរៀល ធៀបនឹង ១៥០,២ពាន់លានរៀល នៅខែកុម្ភៈ ។ ក្នុងនេះ ចំណាយលើរដ្ឋបាលសង្គមកិច្ច កើនស្ទើរទ្វេដងដល់ ៧០,៤ពាន់លានរៀល និងលើរដ្ឋបាលទូទៅ កើនបាន ៥៤% ដល់ ៣២,៩ពាន់លានរៀល ។ លើសពីនេះ ចំណាយលើសន្តិសុខ និងការពារជាតិ កើនបាន ៦៦% ដល់ ៤៤,៦ពាន់លានរៀល រីឯ ចំណាយលើរដ្ឋបាលសេដ្ឋកិច្ច កើនទ្វេដងដល់ ១៣,៨ពាន់លានរៀល ។

In March, current expenditure rose by 20 percent to KHR180 bn, compared to KHR150.2 bn in February. Of this, expenditures on social administration nearly doubled to KHR70.4 bn, and general administration increased by 54 percent to KHR32.9 bn. Expenditures on defence and security rose by 66 percent to KHR44.6 bn, while economic administration expenditure doubled to KHR13.8 bn.

**Current Budget Expenditure**
**January 2005–March 2006**




*Note: Provisional for 2005–2006*
Source: *Monthly Bulletin of Statistics* (MEF)

# សកម្មភាពសេដ្ឋកិច្ចនៃប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅខែឧសភា ការនាំចេញទំនិញរបស់ US និងតំបន់អឺរ៉ូ បានកើនឡើង រីឯការនាំចេញទំនិញរបស់ជប៉ុន ធ្លាក់ចុះ ។ ការនាំចេញរបស់US កើនបន្តិច ពី ៨១,៨៥ពាន់ដុល្លារ ដល់ ៨៤,២១ពាន់លានដុល្លារ ។ ការនាំចេញទំនិញរបស់តំបន់អឺរ៉ូ កើនបាន ៣,៣% ធៀបនឹងខែមុន ដល់ ១៤៥,១៣ពាន់លានដុល្លារ ។ ការនាំចេញទំនិញរបស់ជប៉ុន ធ្លាក់ចុះអស់ ៣,៣% ធៀបនឹងខែមុន មកត្រឹម ៥០,៤០ពាន់លានដុល្លារ ។

In May, goods exports of the US and the Eurozone increased, while goods exports of Japan decreased. US exports rose from USD81.85 bn in April to USD84.21 bn. Eurozone goods exports rose by 3.3 percent from the previous month to USD145.13 bn. Japan's goods exports decreased by 3.3 percent from the previous month to USD50.40 bn.

**Goods Exports: US, Eurozone and Japan**
(USD bn)




Sources: BEA, Eurostat and OECD

នៅខែឧសភា ការនាំចេញទំនិញរបស់កូរ៉េខាងត្បូង កើនបាន ០,៤% ធៀបនឹងខែមុន ដល់ ២៧,៩៤ពាន់លានដុល្លារ និងកើន ២១% ធៀបនឹងពេលដូចគ្នាឆ្នាំមុន ។ នៅខែមេសា ការនាំចេញទំនិញរបស់តៃវ៉ាន់ កើនបាន ០,៧% ដល់ ១៨,៩២ពាន់លានដុល្លារ និងកើន ១៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។

In May, goods exports of South Korea increased by 0.4 percent from the previous month to USD27.94 bn, an increase of 21 percent from the same period last year. Taiwan's goods exports in April increased by 0.7 percent to USD18.92 bn; compared to the same month last year, an increase of 16 percent.

**Goods Exports: South Korea and Taiwan**
(USD bn)




Sources: National statistics department of each country

នៅខែឧសភា ម៉ាឡេស៊ី មានអតិរេកពាណិជ្ជកម្ម ២,១២ពាន់លានដុល្លារ ធៀបនឹង ១,៩ពាន់លានដុល្លារ នៅខែមេសា ។ ការនាំចេញសរុប កើនបាន ៤,៤% ដល់ ១២,៧១ពាន់លានដុល្លារ រីឯ ការនាំចូលសរុប កើន ២,៩% ដល់ ១០,៥៩ពាន់លានដុល្លារ ។ ផលិតផលអគ្គិសនី និងអេឡិចត្រូនិក មានចំនួន ៤៧% នៃការនាំចេញសរុប (៦ពាន់លានដុល្លារ) ។

In May, Malaysia recorded a trade surplus of USD2.12 bn compared to USD1.9 bn in April. Total exports rose by 4.4 percent to USD12.71 bn, while total imports increased by 2.9 percent to USD10.59 bn. Electrical and electronic products accounted for 47 percent of total exports (USD6 bn).

**Malaysia: External Trade**
(USD bn)




Source: Department of Statistics Malaysia

# ស្ថានភាពអតិផរណានៃប្រទេសជាដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

ថ្លៃទំនិញប្រើប្រាស់របស់ជប៉ុន កើនបាន 0,៦% ក្នុងរយៈមួយឆ្នាំដល់ខែឧសភា ។ បើតាម Nihonkezai Shimbun កំណើននេះ បណ្តាលមកពីថ្លៃថាមពលឡើងខ្ពស់ រួមទាំងប្រេងកាត និងសាំង ក៏ដូចជាថ្លៃសេវាឡើងខ្ពស់ ។ ក្នុងកំឡុងពេលដូចគ្នា អតិផរណាទំនិញប្រើប្រាស់នៅ US និងតំបន់អឺរ៉ូ កើនដល់ ៤,២% និង ២,៥% ធៀបនឹង ៣,៥% និង ២,៤% នៅខែមេសា ។

Japan's consumer prices rose by 0.6 percent in the year through May. According to *Nihonkezai Shimbun,* this increase resulted from the higher cost of energy, including kerosene and gasoline, as well as higher service charges. During the same period, consumer inflation in the US increased from 3.5 percent in April to 4.2 percent in May. In the Eurozone, inflation rose from 2.4 percent in April to 2.5 percent, in May.

### Inflation Rates: US, EU & Japan

(percentage prices change over previous year)




*Note: The latest data available are for May 2006.*
Sources: IMF and *Economist* (8–14 July 2006)

ថ្លៃទំនិញប្រើប្រាស់ទូទៅនៅហុងកុង កើនបាន ២,១% នៅខែឧសភា ២00៦ បើធៀបនឹងខែដូចគ្នាឆ្នាំមុន ហើយខ្ពស់ជាងកំនើន ១,៩% នៅខែមេសា ។ រឿងនេះបណ្តាលមកពីកំនើនថ្លៃម្ហូបអាហារទិញហូបក្រៅផ្ទះ និង ថ្លៃគ្រឿងអលង្ការ ក៏ដូចជា ថ្លៃសេវាទូរស័ព្ទនិងទូរគមនាគមន៏ផ្សេងទៀត ។ ក្នុងកំឡុងពេលដូចគ្នា អតិផរណាថ្លៃទំនិញប្រើប្រាស់កើនដល់ ១,៤% នៅចិន និង ២,៤% នៅកូរ៉េខាងត្បូង ។

Hong Kong's overall consumer prices rose by 2.1 percent in May compared to the same month last year, a larger increase than the 1.9 percent recorded in April. This was attributable to increases in the costs of meals bought away from home and the price of jewellery and higher charges for telephone and other communication services. During the same period, consumer inflation increased to 1.4 percent in China and to 2.4 percent in South Korea.

### Inflation Rate: China, Hong Kong & South Korea

(percentage prices change over previous year)




*Note: The latest data available are for May 2006.*
Sources: IMF and *Economist* (8–14 July 2006)

នៅខែឧសភា ២00៦ សន្ទស្សន៏ថ្លៃទំនិញប្រើប្រាស់របស់សិង្ហបូរី កើន ១,១% បើធៀបនឹងខែដូចគ្នា ឆ្នាំមុន ។ យោងតាមនាយកដ្ឋានស្ថិតិសិង្ហបុរី រឿងនេះមកពីការឡើងថ្លៃម្ហូបអាហារ សំលៀកបំពាក់ ស្បែកជើង ផ្ទះ ការអប់រំ សំភារៈការិយាល័យ និងការថែទាំសុខភាព ។ អតិផរណាក្នុងរយៈមួយឆ្នាំ មានកំរិត ៣,៩% នៅម៉ាឡេស៊ី និង ៦,២% នៅថៃ ។

Singapore's consumer price index in May 2006 was 1.1 percent higher than in the same month a year earlier. According to the Department of Statistics of Singapore, this reflected higher costs for foodstuffs, clothing and footwear, housing, education, stationery and health care. Year-on-year inflation was 3.9 percent in Malaysia and 6.2 percent in Thailand.

### Inflation Rate: Selected ASEAN Countries

(percentage prices change over previous year)




*Note: The latest data available are for May 2006.*
Sources: IMF and *Economist* (J8–14 July 2006)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

# Exchange Rates in World Markets

នៅខែកក្កដា ២០០៦ ដុល្លារUS មានការវិវត្តន៍ចំរុះទល់នឹងរូបិយវត្ថុចំបងផ្សេងទៀត ។ ទល់នឹងប្រាក់យ៉េនជប៉ុន វាប្តូរបាន ១១៥,៨យ៉េន/ដុល្លារUS រឺឡើងថ្លៃ ១,0% ធៀបនឹងខែមិថុនា ។ ទល់នឹងអឺរ៉ូ វាប្តូរបាន 0,៧៩អឺរ៉ូ/ដុល្លារUS រឺចុះថ្លៃបន្តិចធៀបនឹងមួយខែមុន ។

In July, movement of the US dollar was mixed against other major currencies. It bought 115.8 Japanese yen, a 1.0 percent appreciation from June. Against the euro, it traded at 0.79 EUR/USD, a marginal depreciation from a month earlier.

**EUR & JPY against USD**

July 05–July 06




Source: Federal Reserve Bank of New York

នៅខែកក្កដា ២០០៦ ប្រាក់វ៉ុនកូរេខាងត្បូង ឡើងថ្លៃបន្តិចទល់នឹងដុល្លារUS ដោយប្តូរបាន ៩៥0,៨១វ៉ុន/ដុល្លារUS ធៀបនឹង ៩៥៤,៤៥វ៉ុន/ដុល្លារUS កាលពីខែមុន ។ ក្នុងកំឡុងពេលដូចគ្នា ដុល្លារហុងកុង ធ្លាក់ថ្លៃបន្តិចទល់នឹងដុល្លារUS ដោយប្តូរបាន ៧,៧៧ដុល្លារហុងកុង/ដុល្លារUS ធៀបនឹង ៧,៧៦ដុល្លារហុងកុង/ដុល្លារUS នៅខែមិថុនា ។

In July 2006, the South Korean won advanced marginally against the US dollar, trading at 950.81 KRW/USD, up from 954.45 KRW/USD a month earlier. During the same period, the Hong Kong dollar lost slightly against its US counterpart, trading at 7.77 HKD/USD, compared to 7.76 HKD/USD in June.

**KRW & HKD against USD**

July 05–July 06




Sources: Federal Reserve Bank of New York

នៅខែកក្កដា ២០០៦ ដុល្លារសិង្ហបុរី ឡើងថ្លៃបន្តិចទល់នឹង ដុល្លារUS ដោយប្តូរបាន ១,៥៨៤ដុល្លារសិង្ហបុរី/ដុល្លារUS ។ ប្រាក់បាតថៃ ក៏ឡើងថ្លៃទល់នឹងដុល្លារUS ដោយប្តូរបាន ៣៧,៩៧បាត/ដុល្លារUS រឺឡើងថ្លៃប្រហែល ១% ធៀបនឹងខែមិថុនា ។

In July, the Singapore dollar gained slightly against the US dollar, trading at 1.584 SGD/USD. The Thai baht also strengthened by about 1 percent against the US dollar, exchanging at 37.97 THB/USD.

**THB & SGD Against USD**

July 05–July 06




Source: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in World Markets

នៅខែមិថុនា ២00៦ ថ្លៃអង្ករពិភពលោក នៅតែដើរតាមនិន្នាការកំនើនដែលកើតមានតាំងពីដើមឆ្នាំមក ។ សន្ទស្សន៍ថ្លៃអន្តរជាតិ (IPO) កើនដល់ ១២៨,៧ពិន្ទុ ធៀបនឹង ១២៦,៩ ពិន្ទុ នៅខែឧសភា ។ នៅសហរដ្ឋអាមេរិក ថ្លៃនាំចេញកើនដល់ ៣៤១,៩៤ដុល្លារ/តោន ធៀបនឹង ៣៣៨,៣១ដុល្លារ/តោន នៅខែឧសភា ។ នៅថៃ ថ្លៃអង្ករ កើន ២% ជាមធ្យម ។ នៅខែមិថុនា អង្ករ Thai 100%B លក់ថ្លៃ ២៨៨,៤៣ដុល្លារ/តោន ដោយកើនពី ២៨២,៩៨ដុល្លារ/តោន នៅខែឧសភា ។

In June, world rice prices held firm following an upward trend since the beginning of the year. The international price index (IPO) rose to 128.7 against 126.9 in May. In the United States, export prices increased to USD341.94 per tonne, against USD338.31 per tonne in May. In Thailand, prices rose by 2 percent on average. In June, Thai 100%B was USD288.43 per tonne, up from USD282.98 in May.

**International Prices Index and Export Rice Prices**
(USD/tonne FOB)




Sources: Osiriz/InfoArroz and InterRice

នៅខែកក្កដា សណ្តែកសៀង និងពោត ឡើងថ្លៃ រីឯប្រេងឆាចុះថ្លៃ ។ សណ្តែកសៀងលក់ថ្លៃ ២១៦,៧0ដុល្លារ/តោន គឺកើនពី ២0៩,៨៣ដុល្លារ/តោន នៅខែមិថុនា ។ ពោត លក់ថ្លៃ ១0៣,0២ដុល្លារ/តោន ដោយកើនពី ៩៩,៧៨ដុល្លារ/តោន នៅខែមិថុនា ។ ប្រេងឆាធ្លាក់ថ្លៃបន្តិច មកត្រឹម ៣៩៦,៣៦ដុល្លារ/តោន នៅខែមិថុនា ធៀបនឹង ៣៩៩,0៨ដុល្លារ/តោន នៅខែឧសភា ។

In July, the prices of soybeans and maize increased, while the price of palm oil decreased. Soybeans sold at USD216.70 per tonne, up from USD209.83 in June. Maize sold at USD103.02 per tonne, up from USD99.78. In June, palm oil went down slightly from USD399.08 in May to USD396.36 per tonne.

**International Prices of Soybean, Maize and Palm Oil**
(USD/tonne FOB)




Source: Food and Agriculture Organisation (FAO)

នៅខែកក្កដា ថ្លៃប្រេងឆៅលក់ដល់ដៃរបស់ OPEC គឺ ៦៩,២៣ដុល្លារ/ធុង ធៀបនឹង ៦៤,៤១ដុល្លារ/ធុង នៅខែមិថុនា ។ ប្រេងសាំងធម្មតា (អុកតាន ៨៧) នៅ US Gulf Coast កើន ៧% ដោយលក់ថ្លៃ ៥៩,៥៧សេនUS/លីត្រ ធៀបនឹង ៥៥,៤0សេនUS/លីត្រ នៅខែមិថុនា ។

In July, the OPEC spot price of crude oil was USD69.23 per barrel, up from USD64.41 in June. The price of regular gasoline (87 octane) on the US Gulf Coast increased by 7 percent to 59.57 US cents per litre, compared to 55.40 US cents in June.

**Prices of Crude Oil and Gasoline**




Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច

# Economic News

***រដ្ឋាភិបាលកម្ពុជាគ្រោងធ្វើឯកជនភាវូបនីយកម្មចំការកៅស៊ូ:*** ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក បានផ្សាយនៅថ្ងៃទី ១២ កក្កដា ២០០៦ ថា រដ្ឋាភិបាលកម្ពុជាគ្រោងធ្វើឯកជនភាវូបនីយកម្មចំការកៅស៊ូរបស់ខ្លួន ដោយមានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី ADB និងនៅពេលកៅស៊ូកំពុងឡើងថ្លៃយ៉ាងខ្លាំង ។ តាមសារព័ត៌មាន Cambodia Daily លោក លី ផល្លា ប្រធាននាយកដ្ឋានដំណាំកៅស៊ូ មានប្រសាសន៍ថា ក្រសួងកសិកម្មកំពុងធ្វើការជាមួយ ADB ដើម្បីលក់ចំការកៅស៊ូចំនួន ៧ នៅខេត្តកំពង់ចាម និងក្រចេះ នៅពាក់កណ្តាលឆ្នាំ ២០០៧ ។ គំរោងនេះ នឹងជួយឱ្យរដ្ឋាភិបាលដោះស្រាយបញ្ហាមានកម្មកររដ្ឋច្រើនពេកនៅចំការកៅស៊ូ ។ លោក Masahiro Otsuka អ្នកគ្រប់គ្រងគំរោងរបស់ ADB និយាយថា ឯកជនភាវូបនីយកម្ម គឺជាផ្នែកមួយនៃគំរោង ADB មួយដែលមានទឹកប្រាក់ ២៥ លានដុល្លារ ។ គាត់លើកទៀតថា រដ្ឋាភិបាលទទួលស្គាល់ពី សក្តានុពលខ្ពស់នៃការបង្កើនចំណូលជាតិពី ការលក់កម្មសិទ្ធិលើសហគ្រាសរដ្ឋ ដោយការបានចំណេញច្រើន ដូចជា ពីការឡើងថ្លៃយ៉ាងលឿននៃកៅស៊ូធម្មជាតិ ។ នៅឆ្នាំនេះ ថ្លៃកៅស៊ូនៅលើទីផ្សារអន្តរជាតិកើនបាន ៥៥% ហើយរំពឹងថាវានឹងបន្តកើនឡើងទៀតដោយសារមានតំរូវការខ្ពស់ ។

***Cambodian government plans to privatise rubber plantations:*** The Cambodian government plans to privatise its rubber plantations with the help of the Asian Development Bank (ADB) amid skyrocketing rubber prices, local media reported on 12 July. The Ministry of Agriculture, Forestry and Fisheries is working with the ADB to sell off by mid-2007 its seven rubber plantations, which are located in Kompong Cham and Kratie provinces. The *Cambodia Daily* quoted the ministry's Rubber Department director, Ly Phalla, as saying, "This plan will help the government handle [the problem of] having too many state rubber workers". ADB project manager Masahiro Otsuka said the privatisation effort is part of a USD25 million ADB project. "The government recognises a large potential for increased national benefits from divestment of state-owned enterprises through increased gains from, for instance, rapid increases in natural rubber prices", he said. This year, the price of rubber on international markets has increased 55 percent and is expected to continue to rise due to high demand, the newspaper said. *(Cited from Xinhua, 12 July 2006)*

***អាស៊ាននឹងចុះកិច្ចព្រមព្រៀងលើការធ្វើដំណើរដោយគ្មានទិដ្ឋាការ:*** សមាជិកប្រទេសអាស៊ាន នឹងអាចធ្វើដំណើរនៅក្នុងតំបន់ដោយមិនចាំបាច់សុំទិដ្ឋាការចាប់ពីខែសីហាទៅ ។ គំនិតផ្តួចផ្តើមនេះ ជាលទ្ធផលនៃការចុះកិច្ចព្រមព្រៀងជាផ្លូវការរបស់អ្នកដឹកនាំនានា លើកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពី ការលើកលែងទិដ្ឋាការ (FAVE)។ តាមសារព័ត៌មាន Philippine Daily Inquirer លោក Syed Hamid Albar រដ្ឋមន្ត្រីក្រសួងការបរទេសម៉ាឡេស៊ីនិយាយថា ប្រទេសអាស៊ានទាំង១០ នឹងជួបគ្នានៅថ្ងៃទី ២៣ កក្កដា ក្នុងកិច្ចប្រជុំប្រចាំឆ្នាំដើម្បីចុះកិច្ចព្រមព្រៀង ។ ប្រទេសអាស៊ានមួយចំនួន ធ្លាប់បានចុះកិច្ចព្រមព្រៀងទ្វេភាគីដែលអនុញ្ញាតឱ្យប្រជាជនរបស់ពួកគេ អាចធ្វើដំណើរដោយគ្មានទិដ្ឋាការរួចទៅហើយ ។ ប្រទេសកុម្មុយនីស ឡាវ និងប្រទេសកាន់កាប់ដោយកងទ័ព មីយ៉ាន់មា ជាភាគីចុះហត្ថលេខាដែលធ្វើឱ្យគេភ្ញាក់ផ្អើល ។ ប្រទេសឯកកោ មីយ៉ាន់មា មិនអនុញ្ញាតឱ្យបរទេសទៅប្រទេសខ្លួនដោយគ្មានទិដ្ឋាកាទេ ហើយប្រទេសវៀតណាម មានកិច្ចព្រមព្រៀងការធ្វើដំណើរដោយគ្មានទិដ្ឋាការ ជាមួយសមាជិកអាស៊ានភាគច្រើន លើកលែងតែ កម្ពុជា និងមីយ៉ាន់មា ។FAVE មានគោលដៅធ្វើឱ្យកិច្ចព្រមព្រៀងទ្វេភាគីទាំងនេះ ក្លាយជាកិច្ចព្រមព្រៀងមានទំរង់តែមួយ ដែលអនុញ្ញាតឱ្យប្រជាជនអាស៊ានអាចធ្វើដំណើរដោយគ្មានទិដ្ឋការ រយៈពេល ២ សប្តាហ៍។ អាស៊ាន រួមមាន ម៉ាឡេស៊ី សិង្ហបុរី ថៃ ហ្វីលីពីន ឥណ្ឌូនេស៊ី កម្ពុជា ឡាវ ប្រ៊ុយណេ មីយ៉ាន់មា និង វៀតណាម ។

***ASEAN To Sign Accord On Visa-Free Travel***: Members of the Association of South-East Asian Nations (ASEAN) can now travel within the region without visas starting August 2006. The initiative is moving forward as a result of the leaders formally signing the ASEAN Framework Agreement on Visa Exemption (FAVE). A report from the *Philippine Daily Inquirer* quoted Malaysian Foreign Minister Syed Hamid Albar as saying that the 10-nation ASEAN would meet on July 23 for its annual meeting and sign the agreement. Some ASEAN members already have bilateral agreements that allow their citizens limited travel without visas. Communist Laos and military-ruled Myanmar are surprise signatories of the accord. The Laos government requires all foreign visitors to secure a visa before entering the country. However, it has a visa-free travel agreement with Cambodia, Malaysia, Vietnam and Singapore. The reclusive Myanmar does not allow any foreign nationals to visit the country without a visa. Vietnam has an existing visa-free travel agreement with most ASEAN members, except Cambodia and Myanmar. FAVE is aimed at standardising these bilateral agreements into a uniform pact that will allow citizens of ASEAN to visit member nations without a visa for a period of two weeks. ASEAN comprises Malaysia, Singapore, Thailand, the Philippines, Indonesia, Cambodia, Laos, Brunei, Myanmar and Vietnam. *(Cited from allheadlinenews.com11$^{th}$ July 2006)*